**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៧១៩ ព.ណ..ករ..

ថ្ងៃ អង្គារ ១៤ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅឲ្យបានជ្រាបថា៖ សហព័ន្ធសភាពាណិជ្ជកម្មនិងឧស្សាហកម្មឥណ្ឌា(FICCI) នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មអនឡាញ ស្តីពី វាយនភណ្ឌ និងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន "The Global Virtual Textile and Home Furnishing Expo" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ ១៨ ខែកញ្ញា ឆ្នាំ ២០២០។

**វិស័យសំខាន់ៗនៃពិព័រណ៍នេះរួមមាន៖**

- សម្លៀកបំពាក់បុរសនិងនារី និងសម្ភារៈបន្ទាប់បន្សំ
- បច្ចេកទេសវាយនភណ្ឌ
- អំបោះ កប្បាស និងកំណាត់ (វត្ថុធាតុដើម)
- គ្រឿងសង្ហារឹម និងសម្ភារៈតុបតែងផ្ទះ
- ស្បែក និងស្បែកជើង
- វត្ថុអនុស្សាវរីយ៍
- ថ្នាំជ្រលក់ពណ៌ និងសារធាតុគីមីផ្សេងៗសម្រាប់ផលិតអំបោះ កំណាត់ សម្ភារៈតុបតែង និងបោះពុម្ព

ព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មអនឡាញនេះមានការចូលរួមពីក្រុមហ៊ុន សហគ្រាសអន្តរជាតិ និងប្រទេសឥណ្ឌា ដែលមានការរៀបចំជំនួបពាណិជ្ជកម្មរវាងក្រុមហ៊ុនសហគ្រាសមកពីជុំវិញពិភពលោក។ សម្រាប់អ្នកចូលរួមតាំងបង្ហាញផលិតផល ឬសេវាកម្មអន្តរជាតិ ត្រូវចំណាយប្រាក់ចំនួន $៦៥០+កម្រៃពន្ធផលិតផល។ សម្រាប់អ្នកបញ្ជាទិញ អាចចុះឈ្មោះចូលរួមដោយឥតគិតថ្លៃ។

ដំណឹងនេះចាត់ទុកជាការអញ្ជើញ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ ពាណិជ្ជករ សេវាករ និងម្ចាស់ក្រុមហ៊ុនវិនិយោគ ដែលកំពុងធ្វើធុរកិច្ចលើវិស័យពាក់ព័ន្ធខាងលើ ហើយមានបំណងចូលរួមផ្សព្វផ្សាយពីផលិតផល ឬ សេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមបំពេញបែបបទ និង ចុះឈ្មោះចូលរួមតាមអនឡាញតាមរយៈគេហទំព័រ: www.ficciglobiz.com

សូមអរគុណ !

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°2719 MOC D/EB

Phnom Penh, 1 September, 2020

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all producers, traders, service providers and entrepreneurs that Federation of Indian Chambers of Commerce & Industry (FICCI) is organizing "The 1st Global Virtual Exhibition-"Global Virtual Textile and Home Furnishing Expo" from 16th -18th September, 2020.

**Main Sectors of above Virtual Exhibition include:**

- Readymade Garments (Men's & Women's); Intimate; Accessories
- Technical Textiles
- Yarns & Cotton and fabrics (Raw Materials)
- Home Furnishing & Home décor (handicrafts, carpets and more)
- Leather and Shoes
- Gifts
- Dyes & Chemical related to Yearns, Fabrics, Home Furnishing and Printing

**Main Components of above Virtual Exhibition include:**

- Indian & International Exhibitors
- Interaction Sessions
- B2bs Meetings with byers invited globally

The cost of participation for the International Exhibitors is $650+GST and the buyer registration is free of charge.

In this regard, the Ministry of Commerce would like to invite all interested entrepreneurs, producers, traders, service providers and investment companies of which their business activities are related to above-mentioned industries, and wish to participate in the event to visit the website: www.ficciglobiz.com

THANK YOU!

ក្រសួងពាណិជ្ជកម្ម